ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ការស្វែងយល់អំពី

# មូលហេតុ

# នៃវិសោធនកម្ម

# រដ្ឋធម្មនុញ្ញ និងច្បាប់

រៀបរៀងដោយ៖ ថាត ចាន់ថា

**Shared by page: Mr. That Chantha**
**https://www.facebook.com/thatchantha**

# សេចក្តីផ្តើម

ទំព័រប្រវត្តិសាស្ត្រកម្ពុជា បានចាប់ផ្តើមបើកឡើងវិញ បន្ទាប់ពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី ២៣ តុលា ឆ្នាំ១៩៩១។ ភាគីជម្លោះកម្ពុជាទាំងអស់រួមជាមួយបណ្តាប្រទេសហត្ថលេខីមួយចំនួនបានចុះហត្ថលេខា លើកិច្ចព្រមព្រៀងសន្តិភាពនេះ ក្នុងគោលបំណងរលត់ភ្លើងសង្គ្រាមដ៏រ៉ាំរ៉ៃ ដែលបានឆាបឆេះឡើងអស់រយៈកាលជាង ពីរទសវត្ស។

ដើម្បីសម្រេចនូវគោលបំណងដ៏ឧត្តុង្គឧត្តមនេះ អង្គការសហប្រជាជាតិ (UNTAC) បានចំណាយថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់ជាងពីរពាន់លានដុល្លារ ក្នុងការរៀបចំដំណើរការសន្តិភាពមួយ តាមរយៈការបោះឆ្នោតជ្រើសរើសអ្នកតំណាងរាស្ត្រជាសកល នៅឆ្នាំ១៩៩៣ ដោយសហការជាមួយភាគីជាជម្លោះទាំងអស់ក្នុងនាមឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (Supreme National Council SNC) ។

ប្រជាជនកម្ពុជាទាំងអស់ បានសំដែងឲ្យសហគមន៍អន្តរជាតិឃើញថា មានការឆ្អែតឆ្អន់នឹងសង្គ្រាមហើយ យល់ឃើញថាមានតែការបោះឆ្នោត តាមបែបរបបលទ្ធិប្រជាធិបតេយ្យទេ ដែលអាចជួយស្តារសេដ្ឋកិច្ចសង្គម ហេតុដូច្នេះហើយ ក្នុងការបោះឆ្នោតជាសកលឆ្នាំ១៩៩៣ នោះមានប្រជាពលរដ្ឋខ្មែរចូលរួមរហូតដល់ជាង ៩០% ព្រោះពួកគេមានសង្ឃឹមយ៉ាងមុតមាំថា ក្រោយពីបានបោះឆ្នោតប្រគល់ អំណាចដឹកនាំប្រទេសដល់គណបក្សនយោបាយណាមួយតាមឆន្ទៈរបស់ពួកគេរួចហើយ សង្គ្រាមបង្ហូរឈាមដណ្តើមអំណាចគ្នានឹងត្រូវបញ្ចប់ការផ្សះផ្សាជាតិ សន្តិភាព នឹងកើតមានឡើងប្រទេសជាតិនឹងឈានទៅរកវឌ្ឍនភាព និងវិបុលភាពរស់នៅប្រកបដោយភាពសុខសាន្ត គ្មានការភ័យព្រួយរត់លូនព្រាត់ប្រាសប្រពន្ធកូនទៀតឡើយទោះ ជាភាគីកម្ពុជាប្រជាធិបតេយ្យបានស្ថិតនៅខាងក្រៅមិនព្រមចូលរួមបោះឆ្នោតក៏ដោយ។

គណបក្សជាច្រើនបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតប៉ុន្តែ ជាលទ្ធផលគឺមានតែគណបក្ស៤ ត្រូវបានប្រជាពលរដ្ឋធ្វើការបោះឆ្នោតជូន ដើម្បីធ្វើជាតំណាងរបស់ខ្លួននៅក្នុងរដ្ឋសភាជាតិ ក្នុងនោះមាន គណបក្ស ហ្វ៊ុនស៊ិនប៉ិច ៥៨កៅអី គណបក្ស ប្រជាជនកម្ពុជា៥១កៅអី គណបក្ស ប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា ១០កៅអី និងគណបក្ស ម៉ូលីណាកាអ្នកតស៊ូខ្មែរ០១កៅអី។

ក្រោយពីការបោះឆ្នោតព្រឹត្តិការណ៍ វិបត្តិនយោបាយបានកើតមានដោយ គណបក្សប្រជាជនកម្ពុជាបានធ្វើបានប្រកាសមិនទទួលលទ្ធផលនៃការបោះឆ្នោត ប៉ុន្តែបន្ទាប់ពីមានកិច្ចសម្របសម្រួល ផ្នែកនយោបាយសភា តំណាងរាស្ត្រត្រូវបានបង្កើតឡើងដើម្បីតាក់តែងសេចក្តីព្រាងរដ្ឋធម្មនុញ្ញគោរពតាមគោលការណ៍ សិទ្ធិមនុស្សប្រជាធិបតេយ្យសេរីពហុបក្ស និងស្មារតីបង្រួបបង្រួមជាតិគ្រប់និន្នាការ

នយោបាយ។ សេចក្តីព្រាងរដ្ឋធម្មនុញ្ញលើកដំបូង មាន១៣ជំពូក១៣៩មាត្រា។ ជំពូកទាំងនេះបានចែងអំពីអធិបតេយ្យ ព្រះមហាក្សត្រសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ របបនយោបាយសេដ្ឋកិច្ច អប់រំ វប្បធម៌ និងសង្គមកិច្ចរដ្ឋសភា រាជរដ្ឋាភិបាលអំណាចតុលាការ ការគ្រប់គ្រងរដ្ឋបាលសមាជជាតិ អានុភាពការសើរើ និងវិសោធនកម្ម រដ្ឋធម្មនុញ្ញ និងអន្តរប្បញ្ញត្តិ ហើយរដ្ឋធម្មនុញ្ញនេះ ត្រូវបានសភា ធម្មនុញ្ញអនុម័ត នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣។ និងត្រូវបាន ព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឲ្យប្រើ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ ប៉ុន្តែ រដ្ឋធម្មនុញ្ញ ដែលធ្វើវិសោធនកម្ម ជាច្រើនលើកជាពិសេសនៅដំណាក់កាលក្រោយ ការបោះឆ្នោតម្តងៗ។ តើការធ្វើវិសោធនកម្មនេះមានប្រវត្តិយ៉ាងណា និងឈរលើមូលហេតុអ្វី? ហើយ ថ្មីៗនេះ តើសំឡេងតម្រូវ ការប្រជុំនិងអនុម័តច្បាប់របស់ រដ្ឋសភាក៏ដូចជាព្រឹទ្ធសភា ដែលបាន ផ្លាស់ប្តូរជាបន្តបន្ទាប់ ជាពិសេស ការប្តូរ ពីមតិភាគច្រើនពីភាគបីទៅជា ៥០%+១ បណ្តាលមកពីកត្តាភាព ចាស់ទុំគំនិតខាងនយោបាយរបស់អ្នកដឹកនាំខ្មែរ ឬ ក៏មកពីថាមានការវិវឌ្ឍជាវិជ្ជមាននៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ឬ ក៏ដោយសារកម្ពុជាបច្ចុប្បន្ន មានស្ថិរភាព នយោបាយ?។

ជាការពិតការវិវឌ្ឍនៃស្ថានភាពនយោបាយនៅកម្ពុជាបច្ចុប្បន្ន វាសមល្មម សម្រាប់អ្នកដឹកនាំនយោបាយទាំងអស់បង្ហាញឆន្ទៈ ឬភាពក្លាហានជឿទុកចិត្តគ្នា សំដែងចៀសវាងឲ្យបាននូវវិបត្តិនយោបាយដែលនាំឲ្យជាប់គាំងក្នុងការបង្កើតរដ្ឋាភិបាលដែល បណ្តាលមកពីគណបក្សនយោបាយមួយចំនួនឆ្លៀតយកភាពចាំបាច់នៃ តម្រូវការសំឡេងពីរភាគបី ដើម្បីអាចប្រសូតរដ្ឋាភិបាលមួយបាន ដោយទាមទារលក្ខខណ្ឌផ្សេងៗក្នុងគោលបំណងបែងចែកអំណាចដល់ក្រុមខ្លួនទន្ទឹមពេលដល់ គណបក្សឈ្នះឆ្នោត ត្រូវការសំឡេងបង្គ្រប់ពីគណបក្សដទៃ។ ប៉ុន្តែការសុខចិត្តកែសម្រួលសំឡេងគាំទ្រមកពីរភាគបីនេះហាក់បីដូចជា មានទស្សនៈនយោបាយច្រើនជាងការសំដែងតែមួយគត់ ដើម្បីដោះភាពទាល់ច្រកខាងនយោបាយ ឬក៏ថាច្រើនជាង ការពង្រឹងប្រសិទ្ធភាពការងាររដ្ឋបាលសាធារណៈ ព្រោះគេសង្កេតឃើញថា ឥទ្ធិពលនៃសំឡេង៥០%+១ បន្ទាប់ពីត្រូវបានប្រកាសឲ្យប្រើភ្លាម ការកែទម្រង់ រដ្ឋបាលសាធារណៈ ទាំងក្នុងស្ថាប័ន នីតិប្បញ្ញត្តិ និង នីតិប្រតិបត្តិ មានសភាពខុសពីធម្មតា ដោយមន្ត្រីក្នុងស្ថាប័នសាធារណៈ មកពីបក្សតែមួយប៉ុណ្ណោះដែលត្រូវបានដកហូតតំណែង។

ដោយសាររបត់នយោបាយនៅកម្ពុជា នៅតែជាចំណុចជាមូលដ្ឋានគ្រឹះ សម្រាប់គណបក្សនយោបាយនីមួយៗយកឈ្នះលើគូប្រជែង ទើបរាល់ការធ្វើច្បាប់ ឬកែប្រែរដ្ឋធម្មនុញ្ញម្តងៗយើងសង្កេតឃើញថា ទិសដៅនយោបាយច្រើនជាមូលហេតុនាំឲ្យមានការធ្វើ វិសោធនកម្មរដ្ឋធម្មនុញ្ញកន្លងមក។

ការធ្វើវិសោធនកម្មយ៉ាងដូច្នេះមិនមែនជាដំណោះស្រាយនៃបញ្ហាទេ និងធ្វើឲ្យបញ្ហានៅតែកើតឡើងដដែលជាដដែល។ បញ្ហានេះយើងអាចមានដំណោះស្រាយមួយសមរម្យ ដោយមិនចាំបាច់ធ្វើវិសោធន

កម្មរដ្ឋធម្មនុញ្ញទេ គឺថាគ្រប់អ្នកនយោបាយទាំងអស់ ជម្រះចោលឲ្យអស់នូវគំនិត មិនទុកចិត្តគ្នារវាងខ្មែរដោយមិនត្រូវចាត់ទុក ថាការយកប្រៀបឈ្នះខាងនយោបាយលើគូប្រជែងដោយប្រើតាមគ្រប់មធ្យោបាយជាជាងការឈ្នះ សម្រាប់ប្រទេសជាតិក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ ដូចនេះដំណោះស្រាយមួយសម្រាប់ដោះស្រាយវិបត្តិដែលធ្លាប់កើតមាននោះ គេគប្បីធ្វើច្បាប់សម្រាប់ឲ្យគណបក្ស ទាំងអស់ ដែលចូលរួមប្រកួតប្រជែង ការបោះឆ្នោតឲ្យទទួលស្គាល់លទ្ធផលការបោះឆ្នោត បន្ទាប់ពីរបាយការណ៍ របស់ក្រុមអ្នកសង្កេតការណ៍ឯករាជ្យ វាយតម្លៃដំណើរការបោះឆ្នោតនោះថា អាចទទួលយកបាន និងបន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានដោះស្រាយអស់នូវរាល់ពាក្យបណ្តឹងនានាទាក់ទង និងវិវាទការបោះឆ្នោតរបស់គណបក្សនយោបាយ៕

# មូលហេតុដែលនាំឲ្យវិសោធនកម្មច្បាប់

ជាការរួមចំណែកនូវការយល់ដឹងផ្នែកច្បាប់បន្តិចបន្តួច កំហុសឆ្គងយ៉ាងណាសូមអធ្យាស្រ័យ។ មុននឹងខ្ញុំបកស្រាយអំពីមូលហេតុដែលនាំឱ្យការធ្វើវិសោធនកម្មនៃច្បាប់នោះ ជាដំបូងត្រូវយល់អត្ថន័យនៃពាក្យ ***"វិសោធនកម្ម"*** ជាមុនសិន។

**វិសោធនកម្ម** *មកពីការផ្សំបញ្ចូលរវាងពាក្យ "វិសោធន" និង "កម្ម" ដែលពាក្យ* ***វិសោធន*** មានន័យថា *ជាការសម្អាត ឬ រំលីង ។ ដូច្នេះវិសោធនកម្ម គឺសំដៅលើអំពើនៃការសម្អាត (តាមន័យសាមញ្ញ)។ ប៉ុន្តែពាក្យ "វិសោធនកម្ម" តាមន័យច្បាប់ គឺសំដៅលើការកែប្រែ។*

**វិសោធនកម្ម** *គឺការកែប្រែនៅក្នុងសេចក្តីព្រាង ច្បាប់ក្នុង(រយៈពេលធ្វើ)អង្គនីតិបញ្ញត្តិ ឬ នៅក្នុងច្បាប់ដែលបាន អនុម័តរួចហើយ ។ ការកែតម្រូវនៃសេចក្តីវែកញែកដែលមានរួចមក ហើយនៅចំពោះមុខតុលាការ ។*

មុននឹងចូលដល់សំនួរថាតើកត្តាអ្វីខ្លះដែលនាំឲ្យមាននូវការធ្វើវិសោធកម្មច្បាប់? ខ្ញុំសូមលើកយកសំនួរមួយយកមកចោទសួរសិន។ ហេតុអ្វីត្រូវយកឡានទៅជួសជុលយកឡានទៅជួសជុល? ដោយសារឡានប្រើលែងកើតឬមួយធ្វើដំណើរទៅឆេះមិនស្រួល ហើយបើកែលែងកើតហួសសម័យបោះវាចោលហើយទិញថ្មីតែម្តង។ច្បាប់ក៏ដូចគ្នាដែរ ពេលរដ្ឋសភាអនុម័តរួចហើយត្រូវយកទៅអនុវត្ត ក្រោយពេលអនុវត្តមានបញ្ហាឬមួយការ វិវត្តន៍សង្គម ទើបកែសម្រួលអោយអនុវត្តបាន។

ការធ្វើវិសោធនកម្មអាចជាការលុបមាត្រាខ្លះ អាចបន្ថែមបទបញ្ញត្តិខ្លះឬមួយក៏ធ្វើការកែសម្រួលខ្លឹមសារចំពោះមាត្រាមួយចំនួនដែល ខ្វះចន្លោះនៅពេលអនុវត្តជាក់ស្តែង ដូចជាពេលថ្មីៗមានធ្វើវិសោធនកម្មលើមាត្រាមួយចំនួនក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ មាត្រា២៤៧ ដីកាដំណោះស្រាយលើកលែងចោទប្រកាន់កាលណាជនប្រព្រឹត្តបទល្មើសនៅតែគេមិនស្គាល់ ហើយការអនុវត្តជាក់ស្តែងចំពោះបទល្មើសព្រៃឈើ ចាប់បានតែឡាននឹងឈើជនល្មើសនៅតែរកមិនឃើញ ដូច្នេះចៅក្រមស៊ើបសួរសម្រេចលើកលែងចោទប្រកាន់ចំពោះជនប្រព្រឹត្តបទល្មើស ឯវត្ថុតាងរឹបអូសជាសម្បត្តិរដ្ឋមិនកើតដោយសារច្បាប់ព្រៃឈើកំណត់ថាត្រូវរឹបអូសដោយសាលក្រម។

បញ្ហានេះនាំអោយអ្នកអនុវត្តច្បាប់ជជែកវែកញែកទីមួយថា លើកលែងចោទលើអញ្ញត្រជនហើយបញ្ជូនវត្ថុតាងទៅតុលាការជំនុំជំរះទី២ ថាបញ្ជូនទៅជំរះមិនបានទេខុសនិងមាត្រា២៤៧ គឺត្រូវអោយ

ទៅក្រមស៊ើបលើកលែងចោទហើយចេញដីការបែអូសហេតុនេះទើបស្នើសុំអោយធ្វើវិសោធនកម្ម។ ការធ្វើវិសោធនកម្មវាកើតឡើងធម្មតានៅពេលដែលច្បាប់នៅទ្រឹងហើយសង្គមរីកចម្រើនបទល្មើស ក៏វិវឌ្ឍន៍ត្រូវកែសម្រួលអោយច្បាប់អោយស្របតាមសង្គម។ការកសាងច្បាប់ឬវិសោធនកម្មដោយពឹងផ្អែកខ្លាំង ទៅតាមឆន្ទៈនយោបាយឃ្លាតឆ្ងាយបច្ចេកទេសច្បាប់នោះ នាំអោយច្បាប់នោះមិនមានអាយុវែងនោះទេ។

## ❖ កត្តាដែលនាំឲ្យមាននូវការធ្វើវិសោធកម្មច្បាប់មានដូចខាងក្រោម ៖

- **ពេលវេលា** : ពេលវេលាបានធ្វើឲ្យមានការធ្វើវិសោធនកម្ម ព្រោះច្បាប់ ឬ រដ្ឋធម្មនុញ្ញចាស់មិនអាចបំរើឲ្យនយោបាយថ្មី ឬ របបថ្មីបានឡើយ។ ឧ. រដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាឆ្នាំ១៩៤៧ វាបំរើឲ្យតែក្នុងសម័យសង្គមរាស្ត្រនិយម តែវាមិនអាចបំរើឲ្យសម័យព្រះរាជាណាចក្រកម្ពុជាទី២ នាពេលបច្ចុប្បន្ននេះបានទេ។
- **បច្ចេកទេស** : បច្ចេកទេសចាស់តម្រូវឲ្យផ្លាស់ប្តូរដោយសារដកការឃើញនូវបច្ចេកទេសថ្មីដោយមានលក្ខណៈគ្រប់គ្រាន់ និង ច្បាស់លាស់ក្នុងការរកឃើញក្នុងការកាត់សេចក្តីទើបធ្វើអោយមានវិសោធនកម្ម។
- **សង្គមមានការវិវត្តន៍** : សង្គមអាចអោយមានការផ្លាស់ប្តូរ ឬ ការធ្វើវិសោធនកម្មជាដាច់ខាតទើបពេលដែលសង្គមថ្មីមានការរីកចំរើន ដូចនេះហើយរដ្ឋធម្មនុញ្ញសង្គមចាស់ មិនអាចបំរើសង្គមថ្មីគ្រប់ជ្រុងជ្រោយឡើយ។ នៅក្នុងសង្គមរស់នៅបច្ចុប្បន្នមានការវិវត្តន៍ជាខ្លាំង ពីសម័យកាលមួយទៅសម័យកាលមួយ ដូច្នេះដោយសារការវិវត្តន៍នេះ វាក៏បានធ្វើឲ្យទម្លាប់ ក៏ដូចជាចរិកលក្ខណៈរបស់បុគ្គលម្នាក់មានការផ្លាស់ប្តូរទៅតាមនោះដែរ។ ដូច្នេះវាច្បាស់ណាស់ថា ការកែប្រែច្បាប់ ឬ វិសោធនកម្មច្បាប់ គឺជាការចាំបាច់បំផុតសម្រាប់គ្រប់គ្រងសង្គមមនុស្សទៅតាមសង្គមជាក់ស្តែង គេហៅថា បច្ចុប្បន្នភាពនៃច្បាប់។
- **វិទ្យាសាស្ត្រ** : ការរីកចម្រើនផ្នែកវិទ្យាសាស្ត្រតម្រូវឲ្យមានការបង្កើត និង ធ្វើវិសោធនកម្ម គឺត្រូវតែតាមអោយទាន់នូវការរីកចម្រើន។
- **ការបង្កើតស្ថាប័ន** : ប្រទេសយើងជាប្រទេសដែលកំពុងដើបពីគតិលោក ហើយឈានទៅរកប្រទេសកំពុងអភិវឌ្ឍន៍ផងដែរ។ ដូច្នេះហើយរាល់អ្វីៗគឺមិនទាន់មានសព្វគ្រប់ទេ អ្វីៗទាំងអស់នោះគឺឋិតនៅក្នុងការកំពុងអភិវឌ្ឍន៍ទាំងអស់ ដូចនេះការអភិវឌ្ឍន៍ស្ថាប័ន គឺជៀសមិនផុតពីការធ្វើវិសោធន៍កម្មនៃច្បាប់បានទេ។ ឧទា. ការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងក្នុងការបង្កើតស្ថាប័នរដ្ឋលេខាធិការអាស៊ាន(មន្ត្រីផ្នែកសេដ្ឋកិច្ច) ដើម្បីធ្វើការតែងតាំងបុគ្គលិកបន្ថែមទៅក្នុងស្ថាប័នរដ្ឋលេខាធិការអាស៊ានជាដើម។
- **ការជាប់គាំងស្ថានភាពនយោបាយ** : បើយើងមើលជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាយើងនាឆ្នាំ១៩៩៣គឺថាប្រទេសយើងមាននូវបញ្ហានយោបាយមួយកើតឡើងដែលពេលប្រទេសកម្ពុជា មាននាយករដ្ឋ

មន្ត្រីផង និង សហនាយករដ្ឋមន្ត្រីផង ដែលបញ្ហានេះហើយដែលទាមទារឲ្យមាននូវការធ្វើវិសោធនកម្មច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៩។

- **ការបង្កើនពន្ធដា** : នៅពេលដែលប្រទេសណាមួយដែលចង់បង្កើនពន្ធដាទៅលើប្រជាជនគឺដាច់ខាតត្រូវតែមាននូវការធ្វើវិសោធនកម្មទៅលើមាត្រាមួយចំនួន ហើយបញ្ហានេះគឺវាស្រ័យទៅនឹងការអនុវត្តន៍ជាក់ស្តែង បើវានៅមានចំណុចខ្វះចន្លោះច្រើនហើយធ្វើអោយមានការពាក់ពន្ធ័ទៅនឹងផលប្រយោជន៍សង្គមជាតិច្រើន គឺគេអាចធ្វើបានគ្រប់ពេល។ ឧទា. នៅប្រទេសកម្ពុជាកាលពីមុនរាជរដ្ឋាភិបាលមិនយកពន្ធផ្ទះឬដីធ្លីពីប្រជាជនទេ តែឥលូវគឺរដ្ឋាភិបាលយកពន្ធនេះព្រោះដើម្បីយកទៅទ្រទ្រង់សេដ្ឋកិច្ចរបស់ប្រទេសជាតិ។
- **ហេតុទាក់ទងនឹងគោលនយោបាយជាតិ** : (ឧទា. ប្រកាសរបស់ក្រសួងការងារ នៃប្រទេសកម្ពុជាទាក់ទងនឹងការកំណត់ប្រាក់ឈ្នួលអប្បរមាសម្រាប់កម្មករកាត់ដេរ)។
- **មូលហេតុនយោបាយ** (ឧទា: គណបក្សទើបនឹងឡើងកាន់អំណាចថ្មីថ្មោង ចង់ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញឲ្យ ស្របទៅនឹងគោលនយោបាយរបស់ខ្លួន)។
- **អនុវត្តការជាក់ស្តែង**
  - ច្បាប់នោះនៅពុំទាន់មានស្ថានទំងន់ទោស នឹងស្ថានសំរាលទោសអោយបានត្រឹមត្រូវ នឹងចំពោះច្បាប់ព្រហ្មទណ្ឌ ៕
  - ច្បាប់ដែលនាំឲ្យអធម្មនុញ្ញភាព
  - ភាពមិនស៊ីចង្វាក់គ្នានៃច្បាប់
  - បញ្ហាពាក់ពន្ធ័ទៅនឹងសន្តិសុខសង្គម
  - ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសជាតិ
  - ច្បាប់នោះបានប្រើពាក្យពេចន៍មិនត្រឹមត្រូវ ឬ មិនសុវ ចំណុច ឬ មិនសមរម្យ ដែលអាចធ្វើឱ្យមានការបកស្រាយផ្សេងគ្នា។

    ឧទាហរណ៍៖ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី បានអនុវត្តកែប្រែពាក្យពេចន៍មួយចំនួនក្នុងក្រមរដ្ឋប្បវេណី។
  - ច្បាប់នោះអធម្មនុញ្ញភាព មានន័យថា មានលក្ខណៈផ្ទុយពីរដ្ឋធម្មនុញ្ញ ។
  - ច្បាប់នោះពិបាកអនុវត្ត ឬ មិនអាចអនុវត្តបាន។

    ឧទារហណ៍៖ នៅក្នុងក្រឹត្យច្បាប់លេខ ៣៨ ចែងថារាល់កិច្ចសន្យាដែលមានតម្លៃចាប់ពី ៥០០០រៀលឡើងត្រូវធ្វើជាលាយលក្ខណ៍អក្សរ។
  - ច្បាប់នោះចែងមានភាពខ្វះចន្លោះណាមួយ ឬ មានន័យមិនគ្រប់គ្រាន់។

- បណ្ដាលមកពីឆន្ទៈនយោបាយ។ ឧទាហរណ៍៖ វិសោធកម្មរដ្ឋធម្មនុញ្ញ ប្ដូរពីការបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តដល់រដ្ឋាភិបាលពីសម្លេង ២ ភាគ ៣ មកជា ៥០% +១ ជាដើម។
- ច្បាប់នោះធ្វើឱ្យមានការលំបាកក្នុងការអនុវត្តច្បាប់ផ្សេងទៀត ជាក់ស្ដែង នៅក្នុងច្បាប់ចរាចរណ៍ជើងគោក ចែងថា រថយន្តដែលមក បង្ករបទល្មើសចរាចរ ត្រូវយកមករក្សាទុករហូតដល់មានការសម្រេចពីតុលាការ ប៉ុន្តែក្នុងច្បាប់ធានារ៉ាប់រង ចែងថា ក្រុមហ៊ុនធានារ៉ាប់រង មានសិទ្ធិរថយន្តរបស់អតិថិជនរបស់ខ្លួន (បច្ចុប្បន្នមិនទាន់វិសោធនកម្មទេ) ។
- ច្បាប់នោះអាចនឹងបង្កចលាចល ឬ ប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណជាដើម និង មានមូលហេតុជាច្រើនទៀត។

**❖ កម្មវត្ថុដែលគេហាមមិនឲ្យធ្វើវិសោធនកម្មមានដូចតទៅ ៖**

- ទំរង់នៃការគ្រប់គ្រងរដ្ឋ
- បូរណភាពដែនដី
- គោលការណ៍សញ្ជាតិ
- នីតិវិធីដែលមានចែងស្រាប់នៅក្នុងការធ្វើការវិសោធនកម្ម។

# ឯកសារពិគ្រោះ

- បទសម្ភាសន៍ជាមួយ អ្នកគ្រូសាស្ត្រាចារ្យ ជុន ចំរើន ដែលជាសាស្ត្រាចារ្យបង្រៀន មុខវិជ្ជា សេចក្តីផ្តើមនីតិ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។
- បទសម្ភាសន៍ជាមួយ លោកសាស្ត្រាចារ្យ សុខ ដាណា ដែលជាសាស្ត្រាចារ្យបង្រៀន មុខវិជ្ជា នីតិរដ្ឋធម្មនុញ្ញ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ការដកស្រង់ចេញពីការបង្រៀនរបស់សាស្ត្រាចារ្យ ជុំ អ៊ឹម មុខវិជ្ជា នីតិរដ្ឋធម្មនុញ្ញនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច កាលពីថ្ងៃអង្គារ ទី០៤ ឆ្នាំ២០១៣។
- បទសម្ភាសន៍ជាមួយ លោកទីប្រឹក្សាច្បាប់អោយប្រធានមន្ទីរនៅខេត្តកំពង់ចាម និង បច្ចុប្បន្នជាទីប្រឹក្សាច្បាប់អោយអភិបាលខេត្តកំពង់ចាម។
- សៀវភៅនីតិរដ្ឋធម្មនុញ្ញ របស់លោកសាស្ត្រាចារ្យ ម៉ុក ដារ៉ា ឆ្នាំ២០១២-២០១៣។
- ក្រុមអ្នកពិភាក្សាអំពីច្បាប់ និង ជំនួញ ។
- កិច្ចពិភាក្សាសួរដេញដូលជាមួយលោក សំ ប៊ុនថុល។
- វចនានុក្រមពាក្យច្បាប់អង់គ្លេស-ខ្មែរ និងខ្មែរ-អង់គ្លេស មានពាក្យសរុប ២៣៤៨ ពាក្យ ដែលពាក្យទាំងអស់នេះដកស្រង់មកពី វចនានុក្រមច្បាប់ អង់គ្លេស-ខ្មែរ របស់អង្គការមូលនិធិអាស៊ីដែលបានបោះពុម្ពនៅឆ្នាំ ១៩៩៧ ។
- ដកស្រង់ចេញពីចំលើយរបស់លោក ស៊ិន លៀងហេង ដែលខ្ញុំបានចោទសួរគាត់
  https://www.facebook.com/photo.php?fbid=330916167039933
  &set=gm.599690153396902&type=1&theater
- A Source of Human Rights Information Sharing in Cambodia
  http://sithi.org/temp.php?url=law_detail.php&lg=kh&id=168
- Encyclopedia Britannica
  http://global.britannica.com/EBchecked/topic/19144/amendment